សួស្តី នៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីការលាងចាន អញ្ចឹងឬក៏ការលាងសម្អាតចាន ដែលជាធម្មតា ក្រោយពេលដែលយើងញ៉ាំអាហាររួច ឬក៏ក្រោយពេលដែលយើងញ៉ាំបាយរួច យើងតែងតែមានចានប្រឡាក់ ឬប្រឡាក់ម្ហូបអាហារនៅលើចានរបស់យើង ឬក៏ប្រឡាក់បាយនៅលើចានរបស់យើង។ អញ្ចឹងដើម្បីឲ្យមានអនាម័យ យើងត្រូវយកចាននោះទៅលាងសម្អាត មុនពេលដែលយើងយកវាទៅទុក ព្រោះថាប្រសិនបើយើងអត់លាងសម្អាតទេ ចាននោះនឹងកខ្វក់ ហើយនៅពេលដែលយើងប្រើប្រាស់ម្តងទៀត វានឹងមានមេរោគ អញ្ចឹងវាអាចធ្វើឲ្យយើងឈឺ ឬក៏អាចធ្វើឲ្យមេរោគចូលទៅក្នុងខ្លួនរបស់យើងបាន ធ្វើឲ្យខូចសុខភាពរបស់យើង អញ្ចឹងដើម្បីរក្សាអនាម័យនៅក្នុងការហូបចុក យើងត្រូវតែលាងចានសម្អាត យើងត្រូវតែលាងសម្អាតចានរបស់យើងជាមុនសិន បន្ទាប់ពីយើងញ៉ាំអាហាររួច ឬក៏បន្ទាប់ពីយើងញ៉ាំបាយរួច ហើយពេលខ្លះគឺយើងលាងសម្អាតចាន មុនពេលដែលយើងយកមកប្រើប្រាស់ គឺដោយសារតែពេលខ្លះ យើង ចានរបស់យើងគឺទុកយូរ ទុកចោលយូរ អញ្ចឹងអាចមានធូលីកាន់ ឬក៏អាចហុយធូលីទៅលើចាន អញ្ចឹងធ្វើឲ្យចានប្រឡាក់ផងដែរ។ អញ្ចឹងមុនពេលដែលយើងយកចានមកប្រើប្រាស់បាន យើងត្រូវតែលាងសម្អាតវាជាមុនសិន ដើម្បីឲ្យអស់ដីឬក៏អស់ធូលី ហើយចំពោះចានដែលយើងប្រើប្រាស់រាល់ថ្ងៃ មុននឹងយើងយកមកប្រើប្រាស់ យើងត្រូវជូតសម្អាតវាជាមុនសិន

អញ្ចឹងនៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការលាងចានដែលប្រើប្រាស់រួច ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញហាងលក់គុយទាវមួយកន្លែង ដែលហាងនោះគឺជាតូបមួយដែលនៅចិញ្ចើមផ្លូវ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានស្ត្រីម្នាក់ គាត់កំពុងតែឈរនៅក្នុងតូបគុយទាវរបស់គាត់ ដែលនៅក្នុងនោះយើងឃើញមានឆ្នាំងគុយទាវ មានចានគុយទាវ គឺមានចានគោមជាច្រើន ដែលដាក់នៅខាងស្តាំដៃស្ត្រីម្នាក់នោះ ហើយមានគ្រឿងផ្សំរសជាតិជាច្រើនដែលនៅក្បែរចានគោមនោះ ដែលនៅចំកណ្តាលគឺជាឆ្នាំងគុយទាវ អញ្ចឹងស្ត្រីម្នាក់នោះ គាត់កំពុងតែដៃម្ខាងកាន់វែក គាត់កាន់វែកដួសគុយទាវចេញពីទឹកឆ្នាំងស៊ុប ដែលឆ្នាំងស៊ុបនៅខាងក្រោមជាប់នឹងរទេះរបស់គាត់ គាត់កំពុងតែដួសសរសៃមី ឬក៏សរសៃគុយទាវដែលស្រុសរួចចេញពីទឹកស៊ុប ដើម្បីដាក់ចូលទៅក្នុងចាន អញ្ចឹងដៃខាងឆ្វេងរបស់គាត់គឺកំពុងតែកាន់ចានគោមមួយ គាត់កាន់ចានគោមមួយនៅក្នុងដៃខាងឆ្វេង ដើម្បីត្រងយកមីដែលដួសចេញពីទឹកស៊ុបនោះ។ នៅខាងក្រោម នៅលើតុរបស់គាត់ ឬក៏នៅលើរទេះរបស់គាត់ គឺមានចានគោមមួយផ្សេងទៀត អញ្ចឹងបានន័យថាហាងមីរបស់គាត់ប្រហែលជាឆ្ងាញ់ ដែលមានភ្ញៀវចូលញ៉ាំច្រើន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់ធ្វើច្រើន គាត់ធ្វើមីច្រើន ឬក៏គាត់ធ្វើមីទឹកស៊ុបច្រើន ដើម្បីបម្រើដល់អតិថិជនរបស់គាត់
ដែលយើងឃើញស្ត្រីម្នាក់នោះគឺគាត់ពាក់អាវពណ៌ខៀវដៃខ្លី ដោយដៃរបស់គាត់ម្ខាងកាន់វែក
និងដៃម្ខាងរបស់គាត់កាន់ចានដើម្បីដាក់គុយទាវ
ដែលគុយទាវរបស់គាត់គឺជាគុយទាវដែលលក់នៅចិញ្ចើមផ្លូវ។ ហើយនៅក្បែរធុងគុយទាវរបស់គាត់
គឺយើងឃើញមានធុងមួយទៀត ឬក៏យើងហៅថាប៉ោត ឬក៏ធុង
ដែលធុងនោះសម្រាប់ដាក់ចានដែលប្រឡាក់
អញ្ចឹងជាទូទៅការលក់គុយទាវគឺគេអត់លាងចានភ្លាមៗទេ គឺលុះត្រាតែគេលក់ចប់ ទើបគេលាងចាន
ដោយសារតែភ្ញៀវច្រើននិងចានច្រើន ដូច្នេះគេលាងអត់ទាន់នោះទេ
អញ្ចឹងអ្នកលក់ត្រូវទិញចានមកឲ្យច្រើន ដើម្បីផ្គត់ផ្គង់ភ្ញៀវ ដើម្បីដាក់ឲ្យភ្ញៀវញ៉ាំឲ្យបានគ្រប់គ្រាន់
ចំណែកឯចានដែលប្រឡាក់គេលាងតាមក្រោយ។ ជាក់ស្ដែងនៅក្នុងរូបភាពនេះ
យើងឃើញនៅលើរទេះមីរបស់គាត់ ឬក៏នៅលើរទេះដែលលក់គុយទាវរបស់គាត់
យើងឃើញមានចានគោមជាច្រើនកំពុងតែតម្រៀបគរលើគ្នា
ចំណែកឯចានប្រឡាក់គឺនៅក្នុងធុងខាងក្រោម គឺក៏មានច្រើនដែរ អញ្ចឹងស្ត្រីម្នាក់នេះ
គាត់គឺជាអ្នកលក់គុយទាវដែលឆ្ងាញ់ គុយទាវរបស់គាត់គឺឆ្ងាញ់ អញ្ចឹងមានភ្ញៀវញ៉ាំគុយទាវគាត់ច្រើន
ដែលជាក់ស្ដែងយើងឃើញនៅលើតុដែលនៅក្បែរធុងគុយទាវ ឬក៏រទេះគុយទាវស្ត្រីម្នាក់នោះ
គឺឃើញមាននារីម្នាក់ ដែលគាត់ពាក់អាវពណ៌ប្រផេះដៃខ្លី គាត់មានសក់វែង
ប៉ុន្តែគាត់ទម្លាក់សក់គាត់ចុះ គាត់កំពុងតែអង្គុយញ៉ាំគុយទាវ
អញ្ចឹងយើងឃើញដៃរបស់គាត់ម្ខាងកាន់ចានមីឡើង ដៃម្ខាងទៀតកាន់ចង្កឹះចាប់សរសៃមីដើម្បីញ៉ាំ
អញ្ចឹងចានមីគាត់កំពុងតែញ៉ាំមី ឬក៏ញ៉ាំគុយទាវស៊ុប ដែលគាត់បានកុម្ម៉ង់ពីស្ត្រីម្នាក់នោះ
ដោយយើងឃើញនៅលើតុរបស់គាត់ គឺមានចានគ្រឿងផ្សំរសជាតិជាច្រើន ដែលមានដូចជាម្ទេស
មានដូចជាអំបិល មានដូចជាស្ករស មានដូចជាប៊ីចេងជាដើម អញ្ចឹងគេដាក់គ្រឿងផ្សំនៅលើតុ
ដើម្បីឲ្យអតិថិជនរបស់គេផ្សំគ្រឿងទៅតាមចិត្តឬទៅតាមរសជាតិដែលគេចូលចិត្ត
ដែលនៅក្នុងរូបភាពនេះ គឺស្ត្រីម្នាក់នោះ គាត់កំពុងតែញ៉ាំគុយទាវ ឬក៏មីទឹកស៊ុបដែលគាត់បានកុម្ម៉ង់
អញ្ចឹងយើងឃើញថាទោះបីជាតូបរបស់គាត់លក់នៅតាមចិញ្ចើមផ្លូវ
ក៏ប៉ុន្តែគុយទាវរបស់គាត់គឺមានរសជាតិឆ្ងាញ់
ដែលធ្វើឲ្យអតិថិជនជាច្រើនមកទិញនូវគុយទាវរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ គឺយើងឃើញមានក្មេងប្រុសម្នាក់ ក្មេងប្រុសនោះ
គាត់មានអាយុប្រហែល ១៥ ឆ្នាំ អញ្ចឹងគាត់នៅក្មេងទេ ក៏ប៉ុន្តែគាត់ត្រូវបានគេជួលមកឲ្យលាងចាន
អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់ស៊ីឈ្នួលលាងចាន យើងហៅថាស៊ីឈ្នួលលាងចាន
ដោយគាត់យកប្រាក់ខែពីស្ត្រីម្ចាស់ហាងដែលលក់គុយទាវ អញ្ចឹងគាត់មកទីនេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីលាងចានឲ្យស្ត្រីម្នាក់នោះ ដែលយើងឃើញគាត់កំពុងតែប្រមូលចានចេញពីលើតុ
អញ្ចឹងនៅពេលដែលអតិថិជនរបស់គាត់ អតិថិជនរបស់ស្ត្រីអ្នកលក់ គាត់ហូបរួចហើយ
គាត់ញ៉ាំរួចរាល់ហើយ អញ្ចឹងគាត់ទុកចាននៅលើតុ ដោយគាត់គ្រាន់តែបង់លុយទៅឲ្យស្ត្រីជាអ្នកលក់
ហើយគាត់អាចទៅកន្លែងផ្សេងទៀតបាន ដោយគាត់ពុំចាំបាច់យកចានទៅទុកនោះទេ។
អញ្ចឹងក្រោយពេលដែលគេញ៉ាំហើយ គេឡើងចេញ ក្មេងប្រុសម្នាក់ដែលជាកម្មករស៊ីឈ្នួលលាងចាន
ឬក៏បុគ្គលិកលាងចាននោះ គាត់ក៏ដើរប្រមូលចានពីលើតុ ដើម្បីដាក់ទៅចូលទៅក្នុងធុងមួយ
ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺក្មេងប្រុសម្នាក់នោះ គាត់កាន់ធុង ដៃម្ខាងរបស់គាត់គឺកាន់ធុង
ឯដៃម្ខាងទៀតរបស់គាត់គឺយកចានប្រមូលពីលើតុដាក់ចូលទៅក្នុងធុង ដែលយើងឃើញ[...]
ចាននៅក្នុងរូបភាពនេះគឺមានពណ៌បៃតង ពណ៌ទឹកក្រូចជាច្រើន ហើយគាត់បានប្រមូលម្តងមួយៗ
ដាក់ចូលទៅក្នុងធុង ចំណែកឯនៅលើតុនៅសល់ចាន ២ ទៀត គឺជាចានពណ៌បៃតង និងមានចង្កឹះ
ម៉ាគូៗ មួយគូៗ នៅក្នុងចាននីមួយៗផងដែរ ដែលនៅលើតុនោះ
ក៏យើងឃើញមានគ្រឿងផ្សំរសជាតិជាច្រើនផងដែរ ដែលដាក់នៅលើតុ។ អញ្ចឹងក្មេងប្រុសម្នាក់នេះ
គាត់ប្រមូលចានពីលើតុ ដែលភ្ញៀវពិសាឬក៏ញ៉ាំគុយទាវរួចរាល់។

បន្ទាប់មករូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ
គាត់ដើរប្រមូលចានពីលើតុគុយទាវដែលភ្ញៀវញ៉ាំរួចរាល់ហើយ គាត់ក៏បានយកធុងចំនួន ២
ដែលដាក់ចានប្រឡាក់នោះមកដាក់ក្បែរខ្លួនគាត់ ហើយគាត់អង្គុយលាងចាន
អញ្ចឹងជាទូទៅការលក់គុយទាវដែលនៅតាមចិញ្ចើមផ្លូវបែបនេះ
គឺយើងអត់មានកន្លែងលាងចានត្រឹមត្រូវនោះទេ។ អញ្ចឹងគាត់អាចអង្គុយនៅតាមចិញ្ចើមផ្លូវ
ដើម្បីលាងចានផងដែរ ដែលអង្គុយនៅក្បែររទេះគុយទាវ ឬក៏នៅក្រោយរទេះគុយទាវ
ដើម្បីលាងចាន គឺគាត់អត់មានបន្ទប់សម្រាប់លាងចានទេ គឺគាត់លាងចានតាមចិញ្ចើមផ្លូវដូចគ្នា
ដែលក្នុងរូបភាពនេះ យើងឃើញក្មេងប្រុសម្នាក់នោះ គាត់ពាក់អាវពណ៌ប្រផេះ ខោជើងខ្លី
អាវរបស់គាត់ដៃខ្លីដែរ គាត់អង្គុយនៅលើកូនកៅអីតូចមួយ ឬក៏កូនជើងម៉ាតូចមួយ ដែលគាត់អង្គុយ
ដាក់ដៃទាំងពីររបស់គាត់ដាក់ទៅលើជង្គង់ ឬក៏អង្គុយក្ដោបក្បាលជង្គង់
ដោយគាត់សម្លឹងទៅមើលធុងចានប្រឡាក់ អញ្ចឹងនៅក្បែរខ្លួនគាត់គឺមានធុងចានប្រឡាក់ចំនួន ២
ដែលភ្ញៀវបានញ៉ាំគុយទាវរួច ឬក៏ញ៉ាំមីទឹកស៊ុបរួច ហើយចានទាំងអស់នោះគឺជាចានប្រឡាក់
ដែលលក់[...]ដាច់ទាំងអស់ អញ្ចឹងគឺ ហាងនោះគឺលក់ដាច់ អញ្ចឹងគឺមានចានប្រឡាក់ច្រើន
ដែលគាត់ត្រូវលាង អញ្ចឹងនៅក្បែរខ្លួនគាត់គឺមានធុងចានប្រឡាក់ចំនួន ២ និងមានចានដែក
ឬក៏កន្ទន់ចំនួន ២ ផងដែរ។ អញ្ចឹងគាត់មានកន្ទន់ ២ គឺកន្ទន់មួយពណ៌លឿង
និងកន្ទន់មួយទៀតពណ៌បៃតងសម្រាប់លាងចាន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់បានប្រមូលចានមកដាក់ក្បែរខ្លួនគាត់ទាំងអស់ហើយ
បន្ទាប់មកគាត់ក៏ចាប់ផ្ដើមអង្គុយដើម្បីលាងចាន។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា ដើម្បីលាងចានបាន
យើងត្រូវតែប្រើប្រាស់ទឹក អញ្ចឹងគាត់ក៏បានបើកទឹកម៉ាស៊ីន ដើម្បីដាក់ចូលចានដែកទាំង ២
ឬក៏កន្ទន់ទាំង ២ អញ្ចឹងកន្ទន់ពណ៌បៃតង គាត់កំពុងតែបើកទឹកដាក់ ចំណែកឯកន្ទន់ពណ៌លឿង
គឺគាត់បានបើកទឹកដាក់ពេញរួចហើយ អញ្ចឹងដើម្បីលាងចានឲ្យបានស្អាត
យើងត្រូវតែលាងម្ដងជម្រះ ២ ទឹក ដើម្បីឲ្យបានស្អាត ព្រោះពេលខ្លះចានប្រឡាក់ខ្លាំង
អញ្ចឹងយើងអត់អាចលាងមួយទឹកបានទេ ហើយទឹកដែលក្មេងប្រុសនេះកំពុងតែប្រើប្រាស់
គឺអាចចេញមកពីប្រភពទឹករដ្ឋ បានន័យថាគាត់លក់នៅកន្លែងចិញ្ចើមផ្លូវពិតមែន
ក៏ប៉ុន្តែក្បែរនោះគឺមានប្រភពទឹកម៉ាស៊ីន អញ្ចឹងគាត់អាចតទុយោ ឬក៏តទុយោចេញពីកន្លែងប្រភពទឹក
ឬក៏ផ្ទះអ្នកជិតខាងដែលនៅក្បែរនោះ ដើម្បីប្រើប្រាស់ទឹករបស់គេ
ហើយគាត់គ្រាន់តែបង់ថ្លៃឈ្នួលទឹកដែលគាត់ប្រើប្រាស់នោះ ទៅឲ្យម្ចាស់ផ្ទះ
ឬក៏ទៅឲ្យរដ្ឋគឺជាការស្រេច អញ្ចឹងគាត់អត់ចាំបាច់លំបាក ដើម្បីយួរទឹកមកពីផ្ទះ
ឬក៏យួរទឹកតាមរទេះមីរបស់គាត់នោះទេ ដោយគាត់គ្រាន់តែបន្តទឹកចេញពីផ្ទះអ្នកជិតខាងនោះ
គឺជាការស្រេចតែម្ដងដើម្បីប្រើប្រាស់ទឹក។ អញ្ចឹងរូបភាពនេះ ក្មេងប្រុសនោះ
គាត់ក៏បានបើកទឹកម៉ាស៊ីន ដើម្បីដាក់ចូលចានដែកទាំង ២ សម្រាប់ធ្វើការលាងចាន។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ គឺក្មេងប្រុសម្នាក់នោះ
គាត់កំពុងតែចាក់សាប៊ូចូលទៅក្នុងចានដែកពណ៌បៃតង
អញ្ចឹងដោយសារតែចាននោះគឺជាចានគុយទាវ និង[ដោយសារតែ]ចាននោះជាចានមី
ដែលប្រឡាក់ទៅដោយទឹកស៊ុបនិងខគោ ដូច្នេះចានគុយទាវ ឬក៏ចានមី គឺភាគច្រើនគឺមានខ្លាញ់
អញ្ចឹងការលាងជម្រះដោយទឹកទទេគឺអត់ស្អាតនោះទេ អញ្ចឹងយើងត្រូវប្រើប្រាស់សាប៊ូផងដែរ
ហើយជាទូទៅគឺយើងតែងតែលាងចានជាមួយនឹងសាប៊ូ ទោះវាអត់ជាប់ខ្លាញ់ក៏ដោយ
ព្រោះថាសាប៊ូអាចកាត់បន្ថយមេរោគដែលនៅជាប់នឹងចាននោះបានយ៉ាងច្រើន
ហើយសាប៊ូអាចធ្វើឲ្យយើងងាយស្រួលក្នុងការលាងជម្រះចានឲ្យបានស្អាតទៀតផង
ព្រោះប្រសិនបើយើងអត់លាយនឹងសាប៊ូទេ ការលាងចានរបស់យើងគឺពិបាក ហើយអត់ស្អាតនោះទេ
អញ្ចឹងមេរោគនៅតោងជាប់នឹងចានដដែល ដូច្នេះដើម្បីឲ្យស្អាតនិងអស់មេរោគ
យើងត្រូវប្រើប្រាស់សាប៊ូដើម្បីលាងចាន ដែលជាក់ស្ដែងក្មេងប្រុសម្នាក់នេះ
គាត់កំពុងតែចាក់ទឹកសាប៊ូចូលទៅក្នុងចានដែករបស់គាត់
អញ្ចឹងសាប៊ូលាងចានយើងអាចប្រើប្រាស់បានជាសាប៊ូទឹកឬក៏សាប៊ូម្សៅផងដែរ ដែលពេលខ្លះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប្រសិនបើយើងអត់មានសាប៊ូទឹក យើងអាចប្រើប្រាស់សាប៊ូម្សៅ ដើម្បីលាងចានរបស់យើងផងដែរ
ប៉ុន្តែប្រសិនបើយើងប្រើប្រាស់សាប៊ូទឹក គឺវាងាយស្រួលក្នុងការលាងជាង
ដោយសារតែសាប៊ូទឹកគឺងាយរលាយនៅក្នុងទឹកនិងមានពពុះច្រើន។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ
គាត់បានលាយទឹកសាប៊ូចូលទៅក្នុងចានដែកពណ៌បៃតងរួចរាល់ហើយ គាត់ក៏បានយកអេប៉ុង
ឬក៏ប្រដាប់ដុសចាន យកមកដុសចានរបស់គាត់ ដោយគាត់ជ្រលក់អេប៉ុងនោះចូលទៅក្នុងទឹកសាប៊ូ
បន្ទាប់មកគាត់យកមកដុសចាន ដោយដាក់ចាននៅលើជង្គង់របស់គាត់
អញ្ចឹងគាត់ដាក់ចានពណ៌ក្រហមមួយ ចានគោម ឬក៏ចានដាក់ទឹកសម្លពណ៌ក្រហម ដាក់នៅលើជង្គង់
បន្ទាប់មកគាត់យកអេប៉ុងឬក៏ប្រដាប់លាងចានមកដុសខាងក្នុងចានរបស់គាត់
ដោយគាត់ជ្រលក់អេប៉ុងឬក៏ប្រដាប់លាងចាននោះ ចូលទៅក្នុងទឹកសាប៊ូឬក៏យកមកដុស
អញ្ចឹងគាត់ខំប្រឹងដុសយ៉ាងខ្លាំង ដោយដុសចាននោះជារង្វង់
ដោយគាត់យកដៃគាត់ដុសជារង្វង់មូលនៅក្នុងចាននោះ ដើម្បីដុសសម្អាតជាតិខ្លាញ់នៅក្នុងចាន
អញ្ចឹងយើងឃើញនៅក្បែរគាត់ គឺមានធុងចំនួន ២ ដែលកំពុងតែដាក់ចានប្រឡាក់
ហើយគាត់បានដុសចាននោះម្តងមួយៗ ដើម្បីសម្អាតវាឲ្យបានស្អាត
ព្រោះថាគាត់ស៊ីឈ្នួលលាងចានគេ អញ្ចឹងគាត់ទទួលប្រាក់ខែ
ដូច្នេះគាត់ត្រូវតែធ្វើការឲ្យគេឲ្យបានស្អាត និងឲ្យបានល្អ
ដើម្បីឲ្យម្ចាស់ហាងមានការទំនុកចិត្តទៅលើគាត់ ជាក់ស្តែងនៅក្នុងរូបភាពនេះ
គឺគាត់កំពុងតែដុសចានដោយយកចិត្តទុកដាក់បំផុត។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីគាត់ដុស
ខំប្រឹងដុសសម្អាតមួយសន្ទុះ ក្រោយមកយើងឃើញចានរបស់គាត់នៅតែប្រឡាក់ដដែល
អញ្ចឹងបានន័យថាចាននោះគឺប្រឡាក់ខ្លាំង គឺប្រឡាក់ខ្លាញ់ ឬក៏ប្រឡាក់ជាតិទឹកស៊ុប ឬក៏ជាតិខច្រើន
ដូច្នេះវាពិបាកនឹងការដុសសម្អាតខ្លាំងណាស់ អញ្ចឹងគាត់ត្រូវតែធ្វើការដុសសម្អាតម្តងទៀត
ដែលនៅក្នុងរូបភាពនេះយើងឃើញថា បន្ទាប់ពីគាត់ដុសបន្តិចក្រោយមក គាត់លើកចានឡើងមើល
ថាតើចាននោះស្អាតហើយឬនៅ អញ្ចឹងប្រសិនបើចានអត់ទាន់ស្អាត គាត់ដុសបន្ថែមទៀត
ប៉ុន្តែបើចានស្អាតហើយ គាត់នឹងយកចាននោះទៅលាងជម្រះដើម្បីយកទៅទុក
អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញក្មេងប្រុសម្នាក់នោះ គាត់យកដៃឆ្វេងរបស់គាត់កាន់ចានឡើង
ហើយគាត់លើកចានឡើងលើ អញ្ចឹងចានដែលគាត់កំពុងតែដុសអម្បាញ់មិញនេះ គាត់លើកឡើងលើ
ហើយពិនិត្យ អញ្ចឹងភ្នែករបស់គាត់មើលយ៉ាងយកចិត្តទុកដាក់ទៅក្នុងចាននោះ
ថាតើចាននោះបាត់អស់ស្នាមប្រឡាក់ហើយឬនៅ ឬក៏លាងជម្រះបានស្អាតហើយឬនៅ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់ក៏បានលើកចាននោះឡើងមើលយ៉ាងយកចិត្តទុកដាក់បំផុត ហើយដៃម្ខាងទៀតរបស់គាត់ គឺជាដៃស្តាំ ដែលគាត់កំពុងតែកាន់អេប៉ុងសម្រាប់លាងចាន អញ្ចឹងប្រសិនបើចាននោះអត់ទាន់ស្អាតល្អទេ គាត់យកអេប៉ុងដែលនៅដៃខាងស្តាំនោះ ដុសចានបន្ថែមទៀត។ អញ្ចឹងនៅក្នុងរូបភាពទី ៧ នេះ ក្មេងប្រុសនោះ គាត់ពិនិត្យមើលថាតើចាននោះគាត់លាងបានស្អាតហើយឬនៅ។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា បន្ទាប់ពីក្មេងប្រុសនោះគាត់បានពិនិត្យមើលចានមួយសន្ទុះ ក្រោយមកគាត់ឃើញថាចានដែលគាត់កំពុងលាងនោះគឺអត់ទាន់ស្អាតទេ អញ្ចឹងនៅមានស្នាមប្រឡាក់ជាច្រើនដែលនៅក្នុងចាននោះ ដែលវាមានជាប់នូវខ្លាញ់ ឬក៏ជាប់នូវចំណីអាហារកាកសំណល់ផ្សេងៗនៅក្នុងចាន អញ្ចឹងធ្វើឲ្យចានអត់ទាន់ស្អាត ដូច្នេះគាត់ក៏ខំប្រឹងដុសម្តងទៀត។ ដោយនៅក្នុងរូបភាពទី ៨ យើងឃើញក្មេងប្រុសម្នាក់នោះ គាត់បានយកចានមកកៀបនឹងជង្គង់របស់គាត់ គាត់យកចានគោមនោះមកកៀបនឹងជង្គង់ រួចហើយដាក់ទឹកសាប៊ូចូលទៅក្នុងចានគោមនោះ ដោយគាត់ដាក់ទឹកសាប៊ូចូលក្នុងចានគោម ហើយគាត់យកប្រដាប់លាងចានរបស់គាត់មកដុសចូលទៅក្នុងចានយ៉ាងខ្លាំង ម្តងនេះគឺគាត់ដុសខ្លាំងៗជាងមុន ដើម្បីឲ្យអស់ស្នាមប្រឡាក់ អញ្ចឹងយើងឃើញគាត់ធ្វើ ទឹកមុខរបស់គាត់គឺប្រឹង ដោយគាត់ញញេញញញ្ញេញ និងភ្នែករបស់គាត់សម្លឹងទៅក្នុងចាន ដោយដៃរបស់គាត់កំពុងតែដុសចាននោះយ៉ាងខ្លាំង គឺគាត់ដុសខ្លាំងៗ ដើម្បីឲ្យអស់ស្នាមប្រឡាក់ និងដើម្បីឲ្យស្អាត អញ្ចឹងប្រសិនបើយើងលាងចានអត់ស្អាតទេ នៅពេលដែលម្ចាស់ហាងគាត់យកចាននោះទៅប្រើប្រាស់ គឺគាត់ប្រើប្រាស់អត់បានទេ ដោយសារតែចានប្រឡាក់ អញ្ចឹងម្ចាស់ហាងនឹងស្តីបន្ទោសប្រសិនបើគាត់លាងអត់ស្អាត ដូច្នេះគាត់ត្រូវធ្វើយ៉ាងណាឲ្យចានដែលគាត់លាងគឺស្អាតទាំងអស់ អញ្ចឹងគាត់នឹងទទួលបានការសរសើរពីម្ចាស់ហាងថាគាត់ធ្វើការដោយយកចិត្តទុកដាក់ ប៉ុន្តែប្រសិនបើចានអត់ស្អាត គាត់នឹងទទួលការស្តីបន្ទោស ហើយភ្ញៀវក៏អត់ចូលហាងរបស់គាត់ទៀតដែរ ដោយសារតែហាងរបស់គាត់គ្មានអនាម័យ ដូច្នេះហើយក្មេងប្រុសម្នាក់នេះ គាត់ត្រូវតែដុសចានឲ្យបានខ្លាំងៗ និងឲ្យបានស្អាត ដើម្បីឲ្យចានទាំងអស់មានអនាម័យ និងម្ចាស់ហាងសរសើរគាត់ថាគាត់ធ្វើការបានល្អ ហើយនិងមានភ្ញៀវចូលមកហាងគាត់បន្ថែមទៀត។

បន្ទាប់មករូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញក្រោយពីគាត់ដុសខ្លាំងៗ ដុសចាននោះខ្លាំងៗម្តងទៀតហើយ អញ្ចឹងគាត់ដុសចាននោះឡើងវិញម្តងទៀតដោយខ្លាំងជាងមុន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយគាត់ប្រើកម្លាំងខ្លាំងជាងមុន ហើយគាត់បានដុសមួយសន្ទុះ
ក្រោយមកគាត់ក៏បានលើកចាននោះពិនិត្យមើលម្តងទៀត អញ្ចឹងគាត់យកដៃឆ្វេងរបស់គាត់កាន់ចាន
ហើយលើកឡើង ហើយភ្នែករបស់គាត់សម្លឹងទៅមើលចាន ហើយពិនិត្យ
អញ្ចឹងលើកនេះគាត់មានទឹកមុខញញឹម ដោយសារតែចាននោះគឺភ្លឺ
បានន័យថាគាត់ដុសអស់ស្នាមប្រឡាក់ហើយ អញ្ចឹងយើងឃើញចានរបស់គាត់គឺមានពន្លឺចែងចាំង
បានន័យថាពន្លឺចែងចាំង បានន័យថាអស់ស្នាមប្រឡាក់ និងមានទឹកតិចៗដែលស្រក់ចុះមក
ដោយសារតែគាត់លាងនឹងទឹកសាប៊ូ ដូច្នេះចាននឹងសើម ហើយមានទឹកស្រក់ចុះមកជាក់ជាពុំខាន
ប៉ុន្តែអ្វីដែលសំខាន់គឺចានរបស់គាត់ គាត់បានដុសស្អាតហើយ
អញ្ចឹងគាត់អង្គុយពិនិត្យមើលចានរបស់គាត់ ដោយយកដៃឆ្វេងលើកចាននោះឡើងលើ
ហើយដៃស្តាំកាន់អេប៉ុងដើម្បីដុសសម្អាតចាន។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ
គាត់បានលាងសម្អាតចានគោមពណ៌ក្រហមនោះស្អាតរួចរាល់ហើយ
អញ្ចឹងគាត់ដុសអស់ជាតិខ្លាញ់និងស្នាមប្រឡាក់នានា ដែលជាប់នៅលើចានរួចរាល់ហើយ
គាត់ក៏បានយកចានគោមនោះមកជ្រលក់នឹងទឹកស្អាត អញ្ចឹងទឹកដែលនៅចានដែក
ឬក៏កន្ទន់ពណ៌លឿង គឺអត់មានដាក់ទឹកសាប៊ូនោះទេ ដោយទឹកនោះគឺជាទឹកសម្រាប់ជម្រះចាន
អញ្ចឹងនៅពេលដែលគាត់លាងនឹងទឹកសាប៊ូរួចរាល់ហើយ ដុសចាននឹងទឹកសាប៊ូរួចរាល់ហើយ
គាត់ក៏បានយកចានគោមដែលគាត់លាងរួចរាល់នោះមកជម្រះនឹងទឹកស្អាត
ដែលនៅចានដែកពណ៌លឿង អញ្ចឹងគាត់បានយកចានគាត់ជ្រលក់ចូលទៅក្នុងចានដែកពណ៌លឿង
រួចហើយក៏គាត់ដុសសម្អាតម្តងទៀត អញ្ចឹងប្រសិនបើយើងអត់ដុសសម្អាតម្តងទៀតទេ
ប្រសិនបើយើងគ្រាន់តែជ្រលក់វាចូលទៅក្នុងទឹក គឺវាអត់ស្អាតជាតិសាប៊ូទេ
អញ្ចឹងសាប៊ូនឹងកាន់ជាប់នៅនឹងចាន ដែលធ្វើឲ្យវាមានធុំក្លិនសាប៊ូ
និងយើងអត់អាចយកទៅដួសអាហារញ៉ាំបានទេ ដោយសារប្រសិនបើមានជាតិសាប៊ូនៅក្នុងចាន
ហើយយើងញ៉ាំអាហារដែលនៅក្នុងចានដែលមានជាតិសាប៊ូ គឺវាធ្វើឲ្យយើងឈឺបាន
គឺវាធ្វើឲ្យយើងខូចសុខភាព ដោយសារតែសាប៊ូគឺអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពយើង
ប្រសិនបើយើងលាងអត់ស្អាត អញ្ចឹងនៅពេលដែលយើងជម្រះចាន
យើងត្រូវតែដុសវាឲ្យបានស្អាតម្តងទៀត ដើម្បីឲ្យចាននោះអស់ជាតិសាប៊ូនិងអស់ក្លិនសាប៊ូចេញ
ហើយអាចយកទៅប្រើប្រាស់ម្តងទៀតបាន។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ
គាត់ជ្រលក់ចានដែលលាងនឹងទឹកសាប៊ូរួចរាល់ហើយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏ជ្រលក់ចានគាត់ចូលទៅក្នុងចានដែកពណ៌លឿង ដើម្បីជម្រះជាតិសាប៊ូនោះចេញ
អញ្ចឹងគាត់ជម្រះបណ្ដើរ គាត់ដុសចាននោះបណ្ដើរ គាត់ដុសឡើងវិញបណ្ដើរ ដើម្បីឲ្យអស់ជាតិសាប៊ូ
អញ្ចឹងដំបូងគាត់លាងជាមួយនឹងសាប៊ូ ដើម្បីឲ្យអស់ជាតិខ្លាញ់
បន្ទាប់មកគាត់យកចានដែលជ្រះជាតិខ្លាញ់នោះទៅជ្រលក់នឹងទឹកស្អាត ដែលអត់មានសាប៊ូ
ដើម្បីលាងជម្រះជាតិសាប៊ូចេញ អញ្ចឹងបន្ទាប់ពីគាត់បានលាងជម្រះជាតិសាប៊ូហើយ
យើងឃើញចាននោះ គឺគាត់កំពុងតែកាន់ចានមួយដែលភ្លឺស្អាត
អញ្ចឹងបានន័យថាចានដែលគាត់កំពុងលាងគឺស្អាតអស់ហើយ បានន័យថាស្អាត
អត់មានស្នាមប្រឡាក់ ហើយក៏អត់មានស្នាម អត់មានក្លិនសាប៊ូទៀតដែរ
គឺគាត់ដុសបានយ៉ាងស្អាតល្អមែនទែន អញ្ចឹងរូបភាពនេះគឺគាត់លាងជម្រះចានបានស្អាត។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ គឺ បន្ទាប់ពីក្មេងប្រុសនោះលាងចានបានស្អាតហើយ
គាត់ក៏បានយកចានដែលលាងរួចរាល់នោះទៅគរទុកនៅលើរទេះ
ដើម្បីឲ្យស្ត្រីអ្នកលក់យកចាននោះទៅប្រើប្រាស់បន្តទៀត អញ្ចឹងគាត់លាងម្ដងមួយៗ
ពីចានប្រឡាក់ដែលនៅក្នុងធុង ដែលយើងឃើញក្បែររទេះលក់មីនោះ គឺយើងឃើញមានធុងមួយ
សម្រាប់ដាក់ចានប្រឡាក់ ហើយនៅលើរទេះលក់មី គឺមានចានស្អាត
ដែលក្មេងប្រុសនោះបានលាងរួចរាល់ហើយដាក់ទៅលើនោះ ដែលយើងឃើញមានចានពណ៌ក្រហម
ពណ៌បៃតងជាដើម ដែលក្មេងប្រុសនោះទើបតែលាងរួចគឺចានពណ៌ក្រហម
អញ្ចឹងគាត់ដាក់ចានពណ៌ក្រហមទៅលើគេ ដើម្បីឲ្យស្ត្រីម្នាក់នោះគាត់យកទៅប្រើប្រាស់
ចំណែកឯនៅក្បែរធុងរទេះគឺយើងឃើញមានកូនធុងមួយ ឬក៏កូនប៉ោតមួយ
សម្រាប់ដាក់ចានប្រឡាក់ដែលនៅក្បែរនោះ អញ្ចឹងក្មេងប្រុសនោះ
ក្រោយពីគាត់លាងចានក្រហមហើយ គាត់ត្រូវយកចានផ្សេងៗទៀតទៅលាងដូចគ្នា
អញ្ចឹងគាត់ត្រូវលាងទាំងអស់ ចំពោះចានដែលប្រឡាក់ ឬក៏ចានឆ្នាំងដែលប្រឡាក់
គាត់ត្រូវលាងចេញទាំងអស់ អញ្ចឹងគាត់លាងម្ដងមួយៗដើម្បីសម្អាតចានដែលប្រឡាក់។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា ក្មេងប្រុសម្នាក់នោះ
គាត់មិនត្រឹមលាងតែចាននោះទេ ដោយសារតែហាងនោះគឺជាហាងលក់មី
អញ្ចឹងសម្ភារៈដែលប្រឡាក់គឺមានដូចជាកែវ មានដូចជាស្លាបព្រា មានដូចជាសម មានដូចជាចង្កឹះ
និងមានដូចជាឆ្នាំងជាដើម គឺត្រូវ គាត់ត្រូវលាងសម្អាតចេញទាំងអស់
អញ្ចឹងរាល់សម្ភារៈណាដែលប្រឡាក់ គឺម្ចាស់ហាងគឺតែងតែឲ្យក្មេងប្រុសនោះប្រមូលយកទៅលាង
អញ្ចឹងនៅក្នុងរូបភាពទី ១៣ នេះ គឺជាសម្ភារៈដែលប្រឡាក់ទាំងអស់
ដែលក្មេងប្រុសនោះបានលាងហើយស្អាត អញ្ចឹងគាត់បានលាងយ៉ាងស្អាត មានដូចជាចានសំប៉ែត

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចានសំប៉ែតដែលយើងប្រើសម្រាប់ដាក់មីឆា ឬក៏បាយឆាសម្រាប់ញ៉ាំ ដែលមានចានគោម
ចានគោមគឺជាចានដែលយើងសម្រាប់ដាក់ទឹកស៊ុប ឬក៏មីទឹកស៊ុបសម្រាប់ញ៉ាំ
អញ្ចឹងនៅពេលដែលយើងចង់ញ៉ាំស៊ុប យើងប្រើប្រាស់ចានគោម នៅពេលដែលយើងចង់ញ៉ាំបាយឆា
គឺយើងប្រើប្រាស់ចានសំប៉ែត ហើយយើងឃើញមានកែវពណ៌បៃតងមួយ
ដែលកូនកែវពណ៌បៃតងគឺសម្រាប់ដាក់ទឹកឲ្យអតិថិជនញ៉ាំ
អញ្ចឹងនៅពេលដែលអតិថិជនចូលទៅក្នុងហាងរបស់គាត់ គាត់ប្រើកូនកែវ
ដើម្បីឲ្យអតិថិជនជួសទឹកញ៉ាំ ហើយយើងឃើញមានកាំបិត និងមានសមផងដែរ
ដើម្បីឲ្យសម្រាប់ញ៉ាំអាហារ យើងឃើញមានចង្កឹះមួយគូ យើងឃើញមានវែកមួយសម្រាប់ដួសបាយ
យើងឃើញមានឆ្នាំងស៊ុប ឆ្នាំងស៊ុបគឺជាឆ្នាំងដែលមានរូបរាងជ្រៅ អញ្ចឹងវាខ្ពស់ខាងៗ
ហើយវាមានជ្រៅ វាមានរូបរាងវាជ្រៅចូលទៅខាងក្រោម ដើម្បីដាក់ទឹកស៊ុបឲ្យបានច្រើន
អញ្ចឹងឆ្នាំងស៊ុបនិងឆ្នាំងខ្ទះគឺមានរាងខុសគ្នាបន្តិច ដោយសារឆ្នាំងខ្ទះគឺវាមានរាងសំប៉ែត
ហើយកោងបន្តិចតែប៉ុណ្ណោះ ដើម្បីសម្រាប់ឆាមី ឬក៏ឆាបាយ ឬក៏ឆាបន្លែ ហើយនិងចៀនសាច់
អញ្ចឹងវាអត់មានផតទៅក្នុងជ្រៅដូចឆ្នាំងទឹកស៊ុបទេ ប៉ុន្តែឆ្នាំងទឹកស៊ុបគឺគេធ្វើឲ្យរាងជ្រៅបន្តិច
ដើម្បីដាក់ទឹកស៊ុបបានច្រើន។ អញ្ចឹងនៅក្នុងរូបភាពទី ១៣ នេះគឺជា តែជាសម្ភារៈផ្ទះបាយ
សម្ភារៈផ្ទះបាយដែលសម្រាប់ឲ្យក្មេងប្រុសម្នាក់នោះគាត់លាងសម្អាតចេញ
ក្រោយពេលដែលអ្នកលក់គាត់ប្រើប្រាស់ហើយប្រឡាក់។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញ បន្ទាប់ពីក្មេងប្រុសម្នាក់នោះ
គាត់លាងសម្អាតចានរបស់គាត់រួចរាល់ហើយ អញ្ចឹងគាត់លាងសម្អាតចាននោះរួចរាល់ហើយ
គាត់ក៏បានចាក់ទឹកដែលគាត់លាងរួចនោះចេញចូលទៅក្នុងទឹកលូ
អញ្ចឹងគាត់អត់ត្រូវចាក់ពាសវាលពាសកាលទៅលើថ្នល់នោះទេ
ដោយសារតែប្រសិនបើគាត់យកទឹកកខ្វក់ ដែលគាត់លាងចានរួចរាល់នោះ
គាត់ចាក់ពាសវាលពាសកាលទៅលើថ្នល់ អញ្ចឹងអាចធ្វើឲ្យថ្នល់នោះសើម
ហើយនៅពេលដែលថ្នល់សើម គឺវាធ្វើឲ្យគគ្រិច ពិបាកក្នុងការធ្វើដំណើរ
ហើយពេលខ្លះប្រសិនបើមានឡានម៉ូតូ គាត់ជិះមកកិនលើទឹកដែលខ្ទាតទៅលើថ្នល់នោះ
អាចធ្វើឲ្យខ្ទាតទឹកប្រឡាក់ទៅដល់អ្នកដទៃបាន ដោយសារតែពេលខ្លះថ្នល់គឺមានដី
អញ្ចឹងប្រសិនបើមានដី ដីប៉ះទឹក នឹងទៅជាភក់ អញ្ចឹងនៅពេលដែលមានម៉ូតូ ឬក៏ឡានជិះកិន
វានឹងខ្ទាតប្រឡាក់ទៅអ្នកដំណើរផ្សេងៗទៀត ហើយម្យ៉ាងវិញទៀតប្រសិនបើយើងចាក់ទឹកសាប៊ូ
ឬក៏ចាក់ទឹកលាងចានទៅលើថ្នល់ វាធ្វើឲ្យថ្នល់នោះរអិល អញ្ចឹងប្រសិនបើយើងជិះម៉ូតូកាត់
ឬក៏ជិះកង់កាត់ទឹករអិល គឺអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន ដោយយើងអាចរអិលដួលកង់
ឬក៏រអិលម៉ូតូដួល ហើយអាចធ្វើឲ្យមានគ្រោះថ្នាក់ មានរបួសផ្សេងៗ ឬក៏អាចបាត់បង់ជីវិតផងដែរ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះដើម្បីរក្សាសុវត្ថិភាពឲ្យអតិថិជន ក៏ដូចជារក្សាសុវត្ថិភាពឲ្យអ្នកធ្វើដំណើរផ្សេងៗ
គឺយើងអត់ត្រូវលាងចានហើយជះចូលទៅក្នុងថ្នល់នោះទេ។ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពទី ១៤
ក្មេងប្រុសម្នាក់នេះ បន្ទាប់ពីគាត់លាងចានរួចរាល់ហើយ
យើងឃើញគាត់លើកចានដែកពណ៌លឿងរបស់គាត់ចាក់ចូលទៅក្នុងលូ
អញ្ចឹងគាត់ចាក់ទឹកដែលនៅក្នុងចានដែកទាំងអស់ចូលទៅក្នុងលូមួយ គាត់ចាក់ចូលទៅក្នុងលូ
គឺគាត់អត់ចាក់ទៅលើថ្នល់នោះទេ ព្រោះដើម្បីកុំឲ្យថ្នល់គគ្រិច អញ្ចឹងគាត់ចាក់ចូលទៅក្នុងលូ
ដូច្នេះលូនឹងមានប្រព័ន្ធលូហូរនាំចូលទៅកន្លែងស្ដុកទឹកគគ្រិច ឬក៏ស្ដុកទឹកកខ្វក់ទុក
អញ្ចឹងនៅពេលដែលគាត់ចាក់ចូលក្នុងលូ ទឹកនោះនឹងហូរចូលទៅកន្លែងស្ដុកទឹកកខ្វក់
ដែលយើងឃើញនៅក្បែរក្មេងប្រុសនោះ គឺមានធុងចានមួយ
ដែលចាននោះគឺជាចានលាងរួចរាល់ហើយ អញ្ចឹងចានដែលគាត់បានលាងរួចរាល់ហើយ
គាត់គរទុកនៅក្នុងធុងនោះ ហើយគាត់យកទឹកមកចាក់ចូលទៅក្នុងលូ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ គឺយើងឃើញថា បន្ទាប់ពីក្មេងប្រុសម្នាក់នោះ
គាត់លាងសម្អាតចានទាំងអស់រួចរាល់ហើយ គាត់ក៏បានលើកចានដែលបានលាងរួច
មកដាក់នៅលើធុងរទេះមី ឬក៏រទេះទឹកស៊ុប អញ្ចឹងគាត់បានលើកចានទាំងអស់នោះ
មកដាក់លើធុងរទេះមី ដើម្បីឲ្យស្ត្រីអ្នកលក់នោះយកចាននោះទៅប្រើប្រាស់បន្តទៀត
ដោយក្មេងប្រុសម្នាក់នោះ គាត់បានលើចានចំនួនបួនមកដាក់លើធុងរទេះមី
ដោយមានចានខាងក្រោមគេគឺពណ៌ក្រហម ចានពីរនៅកណ្ដាលគឺពណ៌បៃតង
និងចានមួយលើគេគឺពណ៌ក្រហមដូចគ្នា អញ្ចឹងគាត់លើកចាននោះដោយដៃពីរ ព្រោះថាគាត់នៅតូច
អញ្ចឹងចានច្រើនគាត់អត់អាចលើកដោយដៃម្ខាងបានទេ ព្រោះប្រសិនបើគាត់លើកដោយដៃម្ខាង
ចាននោះអាចនឹងធ្លាក់បែក ឬក៏អាចធ្លាក់ចេញពីដៃរបស់គាត់ ធ្វើឲ្យចាននោះធ្លាក់បែក
អញ្ចឹងប្រសិនបើធ្លាក់បែក ថៅកែរបស់គាត់នឹងស្ដីបន្ទោស ឬក៏បណ្ដេញគាត់ចេញពីការងារ
អញ្ចឹងគាត់អត់ត្រូវធ្វើឲ្យចានបែកនោះទេ
ដូច្នេះគាត់ត្រូវតែលើកចាននោះដោយប្រុងប្រយ័ត្នជាទីបំផុត។ អញ្ចឹងនៅក្នុងការធ្វើការងារ
យើងត្រូវតែធ្វើការដោយប្រុងប្រយ័ត្ន ដោយការយកចិត្តទុកដាក់ យើងមិនត្រូវធ្វេសប្រហែសនោះទេ
ព្រោះប្រសិនបើយើងធ្វេសប្រហែសយើងអាចនឹងត្រូវមាត់
ឬក៏ធ្វេសប្រហែសយើងអាចនឹងត្រូវថៅកែស្ដីឲ្យ ជាក់ស្ដែងក្មេងប្រុសម្នាក់នេះ
គឺគាត់ធ្វើការរបស់គាត់យ៉ាងយកចិត្តទុកដាក់ ដោយគាត់លាងសម្អាតចានបានយ៉ាងស្អាតល្អ
ហើយចានរបស់គាត់នីមួយៗ គាត់ត្រួតយ៉ាងមានសណ្ដាប់ធ្នាប់
ដើម្បីយកមកឲ្យស្ត្រីដែលជាអ្នកលក់គាត់ប្រើប្រាស់បន្តទៀត។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា ក្មេងប្រុសម្នាក់នោះ
បន្ទាប់ពីគាត់យកចានដែលលាងរួចទៅឲ្យស្ត្រីដែលជាអ្នកលក់មីនោះរួចរាល់ហើយ
គាត់ក៏បានមកអង្គុយដើម្បីលាងចានដទៃទៀត អញ្ចឹងគាត់បានលាងចានផ្សេងៗទៀតដែលប្រឡាក់
ព្រោះថាមីនោះគឺអត់ទាន់ឈប់លក់ទេ គឺគាត់នៅតែលក់បន្ត
ហើយអតិថិជនរបស់គាត់នៅតែបន្តចូលដដែល ដូច្នេះគាត់នៅតែបន្តលាងចានដែលប្រឡាក់
អញ្ចឹងគាត់ដើរប្រមូលពីតុណាដែលអតិថិជនញ៉ាំរួចរាល់ គាត់ដើរប្រមូលចានពីលើតុនោះ
ហើយមកលាងបន្តទៀត ដែលនៅក្នុងរូបភាពនេះ យើងឃើញថា គាត់កំពុងតែអង្គុយ
ហើយកៀបចានរបស់គាត់ដែលប្រឡាក់ទៅនឹងជង្គង់ដើម្បីលាង
ក៏ប៉ុន្តែគាត់បានគិតទៅដល់ម៉ាស៊ីនលាងចានមួយ អញ្ចឹងគាត់គិតថាការលាងចានដោយដៃគឺវាហត់
និងប្រើកម្លាំងបន្តិច ហើយពេលខ្លះគឺយើងលាងអត់បានស្អាតនោះទេ
ដូច្នេះហើយគាត់ក៏បានគិតទៅដល់ម៉ាស៊ីនលាងចាន
គាត់គិតថាប្រសិនបើមានម៉ាស៊ីនលាងចានគឺងាយស្រួល គឺយើងគ្រាន់តែដាក់ចានចូលទៅក្នុងម៉ាស៊ីន
នោះម៉ាស៊ីននឹងលាងសម្អាតចានរបស់គាត់បានយ៉ាងស្អាតតែម្តង
ដែលគាត់ពុំចាំបាច់ត្រូវប្រើកម្លាំងដើម្បីដុសចានរបស់គាត់ចុះឡើងៗ ហើយនិងជម្រះពីរ
បីទឹកនោះទេ ព្រោះវាធ្វើឲ្យគាត់អស់កម្លាំងនិងហត់ អញ្ចឹងដោយសារតែគាត់ជាក្មេង
អញ្ចឹងគាត់អត់សូវមានកម្លាំងច្រើន ដូច្នេះគាត់តែងតែគិតទៅដល់ម៉ាស៊ីន
ដើម្បីឲ្យមានបង្កភាពងាយស្រួលដល់គាត់ក្នុងការធ្វើការ។ ម្យ៉ាងវិញទៀត
ជាទូទៅនៅក្នុងប្រទេសកម្ពុជា គឺយើងអត់ឲ្យប្រើប្រាស់ក្មេង ដើម្បីធ្វើការធ្ងន់ធ្ងរនោះទេ
អញ្ចឹងប្រសិនបើមានការប្រើប្រាស់កម្លាំងពលកម្មក្មេងគឺជារឿងខុសច្បាប់
ដូច្នេះយើងអត់ប្រើប្រាស់ក្មេងដើម្បីធ្វើការងារធ្ងន់ធ្ងរនោះទេ។ ប៉ុន្តែនៅក្នុងរូបភាពនេះ
គឺគាត់គ្រាន់តែមកលាងចាន ដូច្នេះវាមិនមែនជាការងារធ្ងន់ធ្ងរនោះទេ អញ្ចឹងក្មេងប្រុសម្នាក់នេះ
គាត់មកលាងចាននៅពេលទំនេរ ឬក៏ពេលល្ងាច បញ្ចប់ពីការសិក្សា បន្ទាប់ពីការសិក្សារបស់គាត់
គាត់គ្រាន់តែមករកលុយ ឬក៏គាត់គ្រាន់តែមករកលុយដើម្បីចិញ្ចឹមជីវិត
ដោយការលាងចានតាមរទេះគុយទាវតែប៉ុណ្ណោះ អញ្ចឹងការងារនេះមិន[មាន]
មិនមែនជាការងារដែលខុសច្បាប់នោះទេ ហើយគាត់គឺជាក្មេងម្នាក់ដែលល្អ
ដែលគាត់ចេះរកលុយដោយខ្លួនឯង
ដោយគាត់មិនយកពេលវេលាទៅដើរលេងផ្តេសផ្តាសជាមួយនឹងមិត្តភក្តិ
តែគាត់យកពេលវេលាទំនេររបស់គាត់ ដើម្បីមករកលុយផ្គត់ផ្គង់គ្រួសាររបស់គាត់
ក៏ដូចជាផ្គត់ផ្គង់ការសិក្សារបស់គាត់ផងដែរ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.